- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត ១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ ~**

ត្រូវបានបំពាក់ **មេដាយ ការពារ** តាមលំដាប់ថ្នាក់ជូនដល់នាយនគរបាល និងនាយនគរបាលជាតិជាន់ខ្ពស់ចំនួន ៤៦ រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោមៈ

**ក. មេដាយ មាស ការពារ ៖**

| | | | | | |
|---|---|---|---|---|---|
| ១- លោកឧត្តមសេនីយ៍ឯក | គៀត | ច័ន្ទថារិទ្ធ | អត្តលេខ | ០២៤៧ | ប្រធានសេនាធិការដ្ឋាន |
| ២- លោកឧត្តមសេនីយ៍ទោ | សេង | វណ្ណា | អត្តលេខ | ០៣៩២ | ប្រធាននាយកដ្ឋានសរុប-ផែនការ នៃសេនាធិការដ្ឋាន |
| ៣- លោកឧត្តមសេនីយ៍ទោ | យ៉េត | វ៉ាហ្សាក់ | អត្តលេខ | ០១២៣ | អនុប្រធានសេនាធិការដ្ឋាន |
| ៤- លោកឧត្តមសេនីយ៍ទោ | សំ | បូរ | អត្តលេខ | ០៩៥៣ | អនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ |
| ៥- លោកឧត្តមសេនីយ៍ទោ | ធូ | សារី | អត្តលេខ | ០២៣៥ | អនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ |
| ៦- លោកឧត្តមសេនីយ៍ត្រី | ប្រាក់ | គុយឡេង | អត្តលេខ | ០២៣៤ | អនុប្រធាននាយកដ្ឋានបុគ្គលិក |
| ៧- លោកឧត្តមសេនីយ៍ត្រី | ឃី | សាមឿន | អត្តលេខ | ០៦៨០ | អនុប្រធាននាយកដ្ឋានសរុប-ផែនការ នៃសេនាធិការដ្ឋាន |
| ៨- លោកឧត្តមសេនីយ៍ត្រី | គិន | ឡាយ | អត្តលេខ | ០៦២១ | អនុប្រធាននាយកដ្ឋានសរុប-ផែនការ នៃសេនាធិការដ្ឋាន |
| ៩- លោកឧត្តមសេនីយ៍ត្រី | យ៉ុង | សំខាន់ | អត្តលេខ | ០១៦៧៣ | អនុប្រធាននាយកដ្ឋានសរុប-ផែនការ នៃសេនាធិការដ្ឋាន |
| ១០- លោកឧត្តមសេនីយ៍ត្រី | សាន | លុច | អត្តលេខ | ៥៣៨៨៨ | អនុប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ១១- លោកឧត្តមសេនីយ៍ត្រី | ម៉ៅ | និម្មល | អត្តលេខ | ០២០០ | ប្រធានលេខាធិការដ្ឋាន នៃនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ |
| ១២- លោកឧត្តមសេនីយ៍ត្រី | សួ | តាំងឆាយ | អត្តលេខ | ០៧២៧ | អនុប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន |
| ១៣- លោកឧត្តមសេនីយ៍ត្រី | ឡាច | យឺន | អត្តលេខ | ០១៧៧ | ប្រធានលេខាធិការដ្ឋាន នៃនាយកដ្ឋានកណ្តាលនគរបាលព្រំដែន |
| ១៤- លោកឧត្តមសេនីយ៍ត្រី | ទៀង | សារ៉ាត់ | អត្តលេខ | ០៧៥០ | ប្រធានលេខាធិការដ្ឋាន នៃនាយកដ្ឋានកណ្តាលសន្តិសុខ |
| ១៥- លោកឧត្តមសេនីយ៍ត្រី | សែន | សម្បត្តិ | អត្តលេខ | ០៧៤៨ | អនុប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម |

| | | | | | |
|---|---|---|---|---|---|
| ១៦- លោកឧត្តមសេនីយ៍ត្រី | សុខ | ជួរ | អត្តលេខ | ០៧៧៨ | អនុប្រធានមន្ទីរប្រឆាំងគ្រឿងញៀន |
| ១៧- លោកឧត្តមសេនីយ៍ត្រី | ឡាំ | វណ្ណា | អត្តលេខ | ០៨០៣ | អនុប្រធានមន្ទីរប្រឆាំងគ្រឿងញៀន |
| ១៨- លោកឧត្តមសេនីយ៍ត្រី | គីម | យីដេត | អត្តលេខ | ០២៤០៤ | អនុប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ |
| ១៩- លោកឧត្តមសេនីយ៍ត្រី | នង | សុផល | អត្តលេខ | ០៧៤២ | អនុប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ |
| ២០- លោកវរសេនីយ៍ឯក | ហង្ស | សុផាណារ៉ា | អត្តលេខ | ០៦៩៤ | ប្រធានលេខាធិការដ្ឋាន នៃនាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ |
| ២១- លោកវរសេនីយ៍ឯក | អោក | សំណាង | អត្តលេខ | ០៧៩៥ | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល |
| ២២- លោកវរសេនីយ៍ឯក | សៀង | សម្បត្តិ | អត្តលេខ | ០៦៨៩ | អនុប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុង |
| ២៣- លោកវរសេនីយ៍ទោ | ឈុន | ចាន់ថន | អត្តលេខ | ០៩១៩ | នាយការិយាល័យ នៃនាយកដ្ឋានបុគ្គលិក |
| ២៤- លោកវរសេនីយ៍ទោ | ឈឹម | ច័ន្ទសុង | អត្តលេខ | ០១៧២៩ | នាយការិយាល័យ នៃសេនាធិការដ្ឋាន |
| ២៥- លោកវរសេនីយ៍ទោ | ង៉ិន | សុផាត | អត្តលេខ | ០១៣៨៧ | នាយការិយាល័យ នៃនាយកដ្ឋានសន្តិសុខផ្ទៃក្នុង |
| ២៦- លោកវរសេនីយ៍ទោ | ម៉ុល | រិទ្ធ | អត្តលេខ | ២០៣៧៥ | អនុប្រធានលេខាធិការដ្ឋាន នៃនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ |
| ២៧- លោកវរសេនីយ៍ទោ | ច័ន្ទ | សេរីរិទ្ធ | អត្តលេខ | ០៥១៨០ | អនុប្រធានលេខាធិការដ្ឋាន នៃនាយកដ្ឋានកណ្តាលនគរបាលព្រំដែន |
| ២៨- លោកវរសេនីយ៍ទោ | លឹម | ហេងលាង | អត្តលេខ | ០៥៥៤៥ | ជំនួយការអគ្គស្នងការរង និងជាប្រធាននាយកដ្ឋានបុគ្គលិក |
| ២៩- លោកវរសេនីយ៍ទោ | ជៀម | សំអាត | អត្តលេខ | ០៤៧៥០ | ជំនួយការប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ |
| ៣០- លោកវរសេនីយ៍ទោ | ធុច | ខេមរិន្ទ | អត្តលេខ | ០៣៩៩៨ | ជំនួយការ ប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន |
| ៣១- លោកវរសេនីយ៍ទោ | ផៃ | ឈុន | អត្តលេខ | ០១២១៦ | នាយរងការិយាល័យ នៃនាយកដ្ឋានប្រឆាំងភេរវកម្ម |
| ៣២- លោកវរសេនីយ៍ទោ | សេង | សុខា | អត្តលេខ | ០១២៤៧ | នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលការពារបេតិកភ័ណ្ឌ |
| ៣៣- លោកវរសេនីយ៍ត្រី | ស៊ា | វណ្ណចាន់ | អត្តលេខ | ០២៣៣៤ | នាយរងការិយាល័យ នៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន |
| ៣៤- លោកវរសេនីយ៍ត្រី | គង់ | ណារិទ្ធ | អត្តលេខ | ៣៨១៤៥ | នាយរងការិយាល័យ នៃនាយកដ្ឋានចារកម្ម |
| ៣៥- លោកវរសេនីយ៍ត្រី | ហ៊ិន | រិទ្ធី | អត្តលេខ | ៣០៥៩៩ | នាយរងការិយាល័យ នៃនាយកដ្ឋានសន្តិសុខផ្ទៃក្នុង |
| ៣៦- លោកវរសេនីយ៍ត្រី | ធន | ឡាឌី | អត្តលេខ | ៥៦៣៤៧ | នាយរងការិយាល័យ នៃនាយកដ្ឋានសន្តិសុខផ្ទៃក្នុង |
| ៣៧- លោកវរសេនីយ៍ត្រី | ជា | ចិន្តា | អត្តលេខ | ០៥២៨៥ | នាយផ្នែក នៃនាយកដ្ឋានសន្តិសុខផ្ទៃក្នុង |
| ៣៨- លោកអនុសេនីយ៍ឯក | ហម | ចាន់វាសនា | អត្តលេខ | ២៧២៥៤ | នាយរងប៉ុស្តិ៍ នៃនាយកដ្ឋានអន្តោប្រវេសន៍ |
| ៣៩- លោកអនុសេនីយ៍ឯក | អ៊ុ | សុបុណ្ណា | អត្តលេខ | ៥៤៦៦០ | នាយផ្នែក នៃនាយកដ្ឋានចារកម្ម |
| ៤០- លោកអនុសេនីយ៍ទោ | ហ៊ុល | សារ៉ុម | អត្តលេខ | ១២៣៧០ | នាយរងផ្នែក នៃនាយកដ្ឋានសន្តិសុខផ្ទៃក្នុង |
| ៤១- លោកអនុសេនីយ៍ទោ | កែវ | តិស៊ឹម | អត្តលេខ | ៣៤៣០៤ | នាយរងផ្នែក នៃនាយកដ្ឋានអន្តោប្រវេសន៍ |
| ៤២- លោកអនុសេនីយ៍ត្រី | វ៉ៃ | អមរា | អត្តលេខ | ៥៦៧៧១ | មន្ត្រី នៃនាយកដ្ឋានអន្តោប្រវេសន៍ |
| ៤៣- លោកស្រីអនុសេនីយ៍ត្រី | វិបុល | លក្ស្មី | អត្តលេខ | ៦៣២៥២ | មន្ត្រី នៃនាយកដ្ឋានអន្តោប្រវេសន៍ |
| ៤៤- លោកអនុសេនីយ៍ត្រី | យូ | សំណាង | អត្តលេខ | ៥៨១០៣ | មន្ត្រី នៃនាយកដ្ឋានសន្តិសុខផ្ទៃក្នុង |
| ៤៥- លោកព្រិន្ទបាលឯក | សំ | សារឿន | អត្តលេខ | ៣៧៤៨៤ | មន្ត្រី នៃនាយកដ្ឋានសន្តិសុខផ្ទៃក្នុង |
| ៤៦- លោកពលបាលទោ | ជីម | ព្រីង | អត្តលេខ | ៦១១០៦ | មន្ត្រី នៃនាយកដ្ឋានប្រឆាំងភេរវកម្ម |

មាត្រា ២ .

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

*កន្លែងទទួលៈ*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា១ និងមាត្រា២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៥ សសរ

# សេចក្តីសម្រេច
## ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

### ស ម្រេ ច

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវអញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលនៃមេដឹកនាំអាស៊ាន-អាមេរិក ចាប់ពីថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១០ នៅទីក្រុងញូវយ៉ក, សហរដ្ឋអាមេរិក រហូតដល់ពេលសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលរាជធានី អភិបាលគ្រប់ខេត្ត និងឯកឧត្តម **ស ខេង** ត្រូវអនុវត្តសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០១០*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

__កន្លែងទទួល :__
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី* ✓
- *ដូចប្រការ ២*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: ៧០៩ សហវ.ប្រក

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១០

# ប្រកាស

## ស្តីពី

## ការប្រគល់នីតិសម្បទាជាគណនេយ្យករគយ ជូនមន្ត្រីរាជការគយនិងរដ្ឋាករ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋាន ពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពី ការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពី បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

ប្រគល់នីតិសម្បទាជាគណនេយ្យករគយ ជូនមន្ត្រីរាជការគយនិងរដ្ឋាករចំនួន ១២០ រូប ដូចមានរាយនាមក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ២.-**

គណនេយ្យករគយមានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

- អនុវត្តកិច្ចប្រតិបត្តិការគណនេយ្យ និងរដ្ឋបាល តាមបណ្តាអង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធនានា តាមការកំណត់របស់អគ្គនាយកគយនិងរដ្ឋាករកម្ពុជា រាប់បញ្ចូលទាំងការចូលរួមធ្វើផែនការប្រើប្រាស់ឯកសារបោះពុម្ព និងផែនការចំណូល ចំណាយផ្សេងៗ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ។
- គ្រប់គ្រង ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លើការងារប្រមូលចំណូលពន្ធ អាករ ប្រាក់ពិន័យ និងកម្រៃគយ ព្រមទាំងនិមុត្តិធានាគ្រប់ប្រភេទ តាមបទប្បញ្ញត្តិជាធរមាន រាប់បញ្ចូលទាំងការងារផ្ទៀងផ្ទាត់កាតព្វកិច្ចពន្ធ-អាករ សរសេរបង្កាន់ដៃ ការគ្រប់គ្រងប្រាក់ចំណូល និងបញ្ជិកាគណនេយ្យគ្រប់ប្រភេទ ផងដែរ ។
- គ្រប់គ្រងការងារបង់ចំណូលគ្រប់ប្រភេទចូលថវិការដ្ឋឲ្យបានទាន់ពេលវេលាកំណត់ និងមានភារកិច្ចផ្ទៀងផ្ទាត់សលាកប័ត្របង់ប្រាក់ចំណូលគយនានា ជាមួយរតនាគាររៀងរាល់ដំណាច់ខែនីមួយៗ ព្រមទាំងទទួលបន្ទុកគ្រប់គ្រងការចំណាយមានការអនុញ្ញាតផ្សេងៗ របស់អង្គភាពគយពាក់ព័ន្ធផងដែរ ។
- គ្រប់គ្រង ថែរក្សា និងត្រួតពិនិត្យឯកសារគណនេយ្យ និងឯកសារពាក់ព័ន្ធគ្រប់ប្រភេទ ដែលបម្រើឲ្យការងារប្រមូលចំណូលគយ ។
- គ្រប់គ្រងទំនិញដែលស្ថិតក្នុងសន្និធិ និង/ឬ ភណ្ឌាគារគយនានា តាមបទប្បញ្ញត្តិជាធរមាន ។
- ទទួលបន្ទុកគ្រប់គ្រងធ្វើរបាយការណ៍ ព្រមទាំងបូកសរុបការងារគណនេយ្យ រដ្ឋបាល និងស្ថិតិ ឲ្យបានទៀងទាត់ តាមទម្រង់កំណត់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ។
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គនាយកគយនិងរដ្ឋាករកម្ពុជា ។

**ប្រការ ៣.-**

គណនេយ្យករគយមានសិទ្ធិ ដូចខាងក្រោម ៖

- ទំនាក់ទំនង សហការជាមួយបណ្តាអង្គភាពគយ ឬបុគ្គលពាក់ព័ន្ធ ដើម្បីស្រាវជ្រាវ និងប្រមូលឯកសារនានា សម្រាប់តម្រូវការនៃការបំពេញភារកិច្ចរបស់ខ្លួន ។
- រាយការណ៍ដោយផ្ទាល់មកការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ នៃនាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រង និងមកការិយាល័យសវនកម្មផ្ទៃក្នុង នៃលេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋានគយនិង

រដ្ឋាករកម្ពុជា ក្នុងករណីជួបប្រទះនូវឧបសគ្គនានាក្នុងការអនុវត្តតួនាទី និងសិទ្ធិរបស់ខ្លួន ផ្សេងទៀត តាមបទប្បញ្ញត្តិជាធរមាន ។

- ចូលរួមត្រួតពិនិត្យឯកសារ ឬត្រួតពិនិត្យរូបវន្តលើទំនិញនានា ក្នុងករណីយល់ថាចាំបាច់ ដើម្បីផ្ទៀងផ្ទាត់រកភាពមិនប្រក្រតី ឬសំណូមពរផ្សេងទៀត ជាយថាហេតុ ។

**ប្រការ ៤.-**

គណនេយ្យករគយ ត្រូវអនុវត្តតួនាទី ភារកិច្ច និងសិទ្ធិរបស់ខ្លួន តាមការចាត់តាំងប្រគល់ភារកិច្ច និងតាមទីកន្លែងដែលកំណត់ដោយអគ្គនាយកគយនិងរដ្ឋាករកម្ពុជា។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.................. សហវ.......

## បញ្ជីរាយនាមមន្ត្រីរាជការគយនិងរដ្ឋាករ ដែលត្រូវទទួលនីតិសម្បទាជាគណនេយ្យករគយ

(ឧបសម្ព័ន្ធប្រកាសលេខ ៧០៩ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ កញ្ញា ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)

| លេខរៀង | គោត្តនាមនិងនាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | អត្តលេខ | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| 1 | កាឌុល កាន់ដារិទ្ធ | ប្រុស | 17-11-1980 | 1358 | |
| 2 | កៀកជ្រុន ច័ន្ទរិទ្ធិ | ប្រុស | 31-08-1981 | 1298 | |
| 3 | ក្រេង សុខគីម | ប្រុស | 10-09-1982 | 1297 | |
| 4 | កែវ អង្គាម | ប្រុស | 15-02-1979 | 1344 | |
| 5 | កែវ គីមឃន | ប្រុស | 01-11-1975 | 1392 | |
| 6 | កៅ ម៉ៅ | ប្រុស | 17-02-1980 | 1372 | |
| 7 | កោះ និច្ច | ប្រុស | 26-01-1974 | 1289 | |
| 8 | ខណ្ណារ៉ា អេលីត | ប្រុស | 24-03-1983 | 1383 | |
| 9 | ខូវ គីអាន | ប្រុស | 04-11-1984 | 1360 | |
| 10 | ខេង សាំងឡេង | ប្រុស | 04-06-1973 | 1393 | |
| 11 | គីម ណាលី | ស្រី | 15-10-1983 | 1308 | |
| 12 | គីម ឆាត | ប្រុស | 27-12-1977 | 1325 | |
| 13 | គីម សីលា | ប្រុស | 06-01-1984 | 1398 | |
| 14 | គួន សំណាង | ប្រុស | 25-07-1982 | 1387 | |
| 15 | ងួន ផាន់ណា | ប្រុស | 01-08-1981 | 1379 | |
| 16 | ង៉ែត សម្បត្តិ | ប្រុស | 21-12-1978 | 1322 | |
| 17 | ចាប ស៊ុនថារិទ្ធ | ប្រុស | 01-09-1981 | 1304 | |
| 18 | ចេង ឈុន | ប្រុស | 01-12-1976 | 1348 | |
| 19 | ជន់ រចនា | ប្រុស | 10-05-1981 | 1318 | |
| 20 | ជ័យ ពិសិដ្ឋ | ប្រុស | 22-01-1984 | 1377 | |
| 21 | ជ័យ សុខជា | ប្រុស | 15-06-1982 | 1381 | |
| 22 | ជា សំណាង | ប្រុស | 05-10-1980 | 1309 | |
| 23 | ជាស័ក្តិ ថាវរី | ស្រី | 08-03-1977 | 1314 | |

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

| | | | | | |
|---|---|---|---|---|---|
| 24 | ជា សំអុន | ប្រុស | 04-01-1979 | 1332 | |
| 25 | ជាវ ចាន់ធូ | ប្រុស | 21-02-1979 | 1391 | |
| 26 | ជ្រិន សំអាត | ប្រុស | 16-08-1974 | 1333 | |
| 27 | ឈិន សុភក្តិ | ប្រុស | 02-01-1982 | 1317 | |
| 28 | ឈុន អង្គារដ្ឋា | ប្រុស | 02-03-1980 | 1354 | |
| 29 | ឈុំ សុភា | ប្រុស | 11-11-1978 | 1326 | |
| 30 | ឈុំ សុវណ្ណ | ប្រុស | 09-10-1980 | 1403 | |
| 31 | ញ៉ឹម ដាលុច | ប្រុស | 26-03-1979 | 1328 | |
| 32 | ញ៉ែម ពុធថុនា | ប្រុស | 13-06-1980 | 1362 | |
| 33 | ញ៉ែម សុមេធ | ប្រុស | 02-02-1977 | 1386 | |
| 34 | ណុប អមរិទ្ធ | ប្រុស | 27-02-1980 | 1374 | |
| 35 | ណាំ សុលាង | ប្រុស | 01-06-1976 | 1310 | |
| 36 | ទន់ ពុទ្ធីមាន | ស្រី | 02-04-1982 | 1373 | |
| 37 | ទិត សំរេច | ប្រុស | 10-05-1975 | 1366 | |
| 38 | ទិ ច័ន្ទទីតា | ស្រី | 20-01-1981 | 1376 | |
| 39 | ទិត្យ កាល្លីណា | ប្រុស | 28-04-1981 | 1401 | |
| 40 | ទូច ស៊ីសុវណ្ណ | ប្រុស | 19-11-1983 | 1357 | |
| 41 | ទុំ មុនីរ័ត្ន | ប្រុស | 26-04-1972 | 1302 | |
| 42 | ទុំ សារិទ្ធិដា | ស្រី | 05-10-1979 | 1349 | |
| 43 | នាង រិទ្ធ | ប្រុស | 18-05-1973 | 1313 | |
| 44 | នាង សុវត្ថារ៉ា | ប្រុស | 08-09-1980 | 1407 | |
| 45 | នួន ចាន់វ៉ាន់ដា | ប្រុស | 0808-1973 | 1299 | |
| 46 | ប៉ាង ពិសិដ្ឋ | ប្រុស | 25-05-1982 | 1371 | |
| 47 | ប៉ុល សេរីបុត្រ | ប្រុស | 07-05-1981 | 1365 | |
| 48 | ប៉ែន ច័ន្ទសង្វាត | ស្រី | 19-04-1982 | 1334 | |
| 49 | ប៊ិន ដា | ប្រុស | 02-06-1974 | 1400 | |
| 50 | ប៊ុន្នី សុជាតា | ស្រី | 02-03-1983 | 1327 | |
| 51 | ប៊ូ សុធារិទ្ធ | ប្រុស | 30-08-1982 | 1295 | |
| 52 | ប៊ូរ វង្សសំណាង | ប្រុស | 13-09-1979 | 1305 | |
| 53 | ផាត់ សុផល | ប្រុស | 05-01-1980 | 1339 | |
| 54 | ផាន់ ម៉េងហ៊ាង | ប្រុស, | 28-07-1978 | 1351 | |
| 55 | ផេង សុខ | ប្រុស | 10-07-1976 | 1340 | |
| 56 | ផេង ប៊ុនថន | ប្រុស | 15-05-1973 | 1394 | |
| 57 | ពិត សារិត | ប្រុស | 07-06-1974 | 1405 | |

| | | | | | |
|---|---|---|---|---|---|
| 58 | ពេជ លីណា | ប្រុស | 20-07-1981 | 1390 | |
| 59 | ពេជ វ៉ាន់ធី | ប្រុស | 10-10-1975 | 1395 | |
| 60 | ព្រំ សីហា | ប្រុស | 16-08-1981 | 1294 | |
| 61 | ព្រំ លីម | ប្រុស | 07-12-1977 | 1320 | |
| 62 | មន្ត មុីរិយ៉ា | ប្រុស | 23-03-1983 | 1338 | |
| 63 | មាស សំអាង | ប្រុស | 23-09-1982 | 1292 | |
| 64 | ម៉ម ម៉ុន | ប្រុស | 11-10-1979 | 1350 | |
| 65 | មុយ បញ្ញារិទ្ធ | ប្រុស | 01-09-1978 | 1384 | |
| 66 | ម៉ាក់ វិសាល | ប្រុស | 02-12-1980 | 1311 | |
| 67 | ម៉េង ផល្លួន | ប្រុស | 17-04-1979 | 1368 | |
| 68 | ម៉ែន ស៊ីថា | ប្រុស | 06-10-1978 | 1347 | |
| 69 | ម៉ៅ ភិរម្យ | ប្រុស | 24-08-1982 | 1361 | |
| 70 | ម៉ៅ ណារ៉ា | ប្រុស | 10-08-1981 | 1406 | |
| 71 | យ៉េន ដាំណែត | ស្រី | 06-06-1982 | 1375 | |
| 72 | យ៉ែម ប៊ុនថា | ប្រុស | 07-01-1975 | 1355 | |
| 73 | រ៉ុត រ័ត្នគិរី | ស្រី | 10-01-1981 | 1346 | |
| 74 | រ៉េង រដ្ឋា | ប្រុស | 13-04-1981 | 1389 | |
| 75 | លន ចិត្រា | ប្រុស | 01-11-1973 | 1307 | |
| 76 | លី ម៉េងឃាង | ប្រុស | 03-08-1976 | 1288 | |
| 77 | លី ស៊ីដេន | ប្រុស | 28-10-1980 | 1306 | |
| 78 | វ៉ិន ម៉ៅ | ប្រុស | 27-11-1972 | 1397 | |
| 79 | វ៉ាន់ បូរិន | ប្រុស | 08-08-1979 | 1353 | |
| 80 | សរ វិចិត្រ | ប្រុស | 30-06-1981 | 1324 | |
| 81 | ស សាវ៉ាត់ | ប្រុស | 25-08-1981 | 1359 | |
| 82 | សាផុន សុផាណ្ណារិន | ប្រុស | 15-11-1981 | 1343 | |
| 83 | សុខ ចំណាន | ប្រុស | 23-12-1981 | 1300 | |
| 84 | សុខ រតនា | ប្រុស | 22-07-1981 | 1323 | |
| 85 | សុខ សុធីរៈ | ប្រុស | 25-07-1982 | 1363 | |
| 86 | សឿ សោភ័ណ | ប្រុស | 24-06-1983 | 1336 | |
| 87 | សេង សុបញ្ញា | ប្រុស | 04-01-1980 | 1378 | |
| 88 | សេង ម៉េងស្រ៊ាន់ | ប្រុស | 18-10-1980 | 1388 | |
| 89 | សំអុន សំរេច | ប្រុស | 19-06-1983 | 1321 | |
| 90 | សំ វុទ្ធី | ប្រុស | 07-05-1980 | 1380 | |
| 91 | សាំង សុខា | ប្រុស | 06-10-1980 | 1341 | |

| | | | | | |
|---|---|---|---|---|---|
| 92 | ស៊ាន រដ្ឋា | ប្រុស | 24-12-1981 | 1290 | |
| 93 | ស្រួយ ព្រើត | ប្រុស | 10-02-1979 | 1303 | |
| 94 | ហាម នី | ប្រុស | 16-05-1974 | 1385 | |
| 95 | ហុក កុម្ភៈ | ប្រុស | 02-02-1979 | 1301 | |
| 96 | ហុង បូណោ | ប្រុស | 07-05-1980 | 1402 | |
| 97 | ហូ សុភក្ត្រា | ប្រុស | 01-09-1980 | 1342 | |
| 98 | ហូ ស្រស់វរលក្ខណ៍ | ប្រុស | 15-05-1977 | 1364 | |
| 99 | ហួង ធីតា | ប្រុស | 23-08-1979 | 1287 | |
| 100 | ហួង រតនា | ប្រុស | 18-09-1981 | 1315 | |
| 101 | ហួយ សុខា | ស្រី | 17-08-1980 | 1396 | |
| 102 | ហេង យូស៊ា | ប្រុស | 06-01-1979 | 1319 | |
| 103 | ហេង មករា | ប្រុស | 05-01-1976 | 1367 | |
| 104 | ហេង សុភា | ប្រុស | 06-08-1977 | 1408 | |
| 105 | ហែម សុភ័ក្ត្រ | ប្រុស | 02-10-1980 | 1356 | |
| 106 | ហោ ស៊ុណាត | ប្រុស | 19-04-1982 | 1331 | |
| 107 | ហ៊ន បូរ៉ា | ប្រុស | 30-07-1970 | 1335 | |
| 108 | ហ៊ាន វណ្ណៈ | ប្រុស | 23-04-1980 | 1330 | |
| 109 | ឡា វិសិដ្ឋ | ប្រុស | 13-02-1980 | 1399 | |
| 110 | ឡាយ ឆវ័នឌីម៉ា | ប្រុស | 03-12-1983 | 1345 | |
| 111 | អាត អឿន | ប្រុស | 27-07-1974 | 1329 | |
| 112 | អោម សុភៈ | ប្រុស | 18-07-1973 | 1337 | |
| 113 | អ៊ាង សរីម | ប្រុស | 29-11-1974 | 1369 | |
| 114 | អ៊ី ណារិទ្ធ | ប្រុស | 18-04-1980 | 1370 | |
| 115 | អ៊ុយ សារីណែត | ស្រី | 07-02-1982 | 1291 | |
| 116 | អ៊ុក គឹមសៀ | ប្រុស | 15-07-1978 | 1293 | |
| 117 | អ៊ុច ចំណាន | ប្រុស | 19-12-1980 | 1296 | |
| 118 | អ៊ុន ហេម៉ាលីន | ប្រុស | 29-07-1974 | 1312 | |
| 119 | អ៊ុក សូរិយា | ស្រី | 25-08-1983 | 1352 | |
| 120 | អ៊ុក វណ្ណឫទ្ធិ | ប្រុស | 31-10-1979 | 1382 | |

បានបញ្ឈប់បញ្ជីត្រឹមលេខរៀងទី ១២០ ( មួយរយម្ភៃ ) ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

គណៈកម្មការមូលបត្រកម្ពុជា

លេខ: ៤៤ ប.ក.ក.ស.ម.ក.ក/១០

លិខិតចូល ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០

ប្រកាសរួម

ស្តីពី

ការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌

* * * * *

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការចាំបាច់

## សម្រេច

**ប្រការ ១.-**

ត្រូវបានផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ដល់មន្ត្រីរាជការដែលបម្រើការងារនៅគណៈកម្មការមូលបត្រកម្ពុជា ដូចខាងក្រោម ÷

១-ឯកឧត្តម **មីញ ចាន់កុសល** អគ្គនាយក នៃគណៈកម្មការមូលបត្រកម្ពុជា

២-ឯកឧត្តម **ស៊ូ សុជាតិ** អគ្គនាយករង នៃគណៈកម្មការមូលបត្រកម្ពុជា

៣-ឯកឧត្តម **កៅ ថាច** អគ្គនាយករង នៃគណៈកម្មការមូលបត្រកម្ពុជា

៤-ឯកឧត្តម **ហួត ពុំ** អគ្គនាយករង នៃគណៈកម្មការមូលបត្រកម្ពុជា

៥-លោក **សៀង ធីរិទ្ធ** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត នៃគណៈកម្មការមូលបត្រកម្ពុជា

**ប្រការ ២.-**

មន្ត្រីនគរបាលយុត្តិធម៌ដែលមានកំណត់ក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន នៅលើវិសាលភាពដែនដីព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.-**

មុននឹងបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ដូចមានកំណត់នៅក្នុងប្រការ ១ ខាងលើ ត្រូវធ្វើសម្បថនៅចំពោះមុខសាលាឧទ្ធរណ៍។

**ប្រការ ៤.-**

មន្ត្រីនគរបាលយុត្តិធម៌ដែលមានកំណត់ក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតដែលនៅជាធរមាន។

**ប្រការ ៥.-**

សាមីខ្លួនដូចមានកំណត់ក្នុងប្រការ ១ ខាងលើ និងស្ថាប័នពាក់ព័ន្ធទាំងអស់ មានភារកិច្ចអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**អង្គ វង្សវឌ្ឍនា**

**កន្លែងទទួល :**

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- តុលាការកំពូល
- មហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍
- មហាអយ្យការអមសាលាឧទ្ធរណ៍
- សាលាដំបូងខេត្ត-រាជធានី
- អយ្យការអមសាលាដំបូងខេត្ត-រាជធានី
- គ្រប់ក្រសួង-ស្ថាប័ន
- សាលាខេត្ត-រាជធានី
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ: ០០៤.............គ.ម.ក.ប្រក

លិខិតចូល

ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ20១០

# ប្រកាស

## ស្តីពី

## ខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ ផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ

* * * * *

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ Phone : 855-23-885-611
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២ Fax : 855-23-885-622
E-mail : info@secc.gov.kh

# ស ម្រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-** គោលបំណង

ប្រកាសនេះមានគោលដៅកំណត់នូវ ខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-** និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ÷

-ច្បាប់ (Law) សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

-អនុក្រឹត្យ (Anukret) សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

-វិធានប្រតិបត្តិការ (Operating Rules) សំដៅដល់វិធានប្រតិបត្តិការ និងនីតិវិធីរបស់ទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ។ វិធានប្រតិបត្តិការមានចែងនូវវិធាននិងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការ របស់ប្រតិបត្តិករនីមួយៗ វិធាននិងនីតិវិធីសម្រាប់គ្រប់គ្រងសមាជិកភាពនិងការចូលរួមក្នុងទីផ្សារ និងលក្ខន្តិកៈរបស់ប្រតិបត្តិករនីមួយៗ។ វិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រមានចែងបន្ថែមនូវវិធានចុះបញ្ជីរបស់ទីផ្សារមូលបត្រ។

-កិច្ចព្រមព្រៀងសេវា (Service agreement) សំដៅដល់កិច្ចព្រមព្រៀងនៃការផ្ដល់សេវាដែលរៀបចំធ្វើឡើងរវាងសមាជិកនិងអ្នកចូលរួមក្នុងទីផ្សាររបស់ប្រតិបត្តិករនីមួយៗ និងអតិថិជនរបស់ខ្លួន។

## ជំពូកទី ២
## មាតិកាគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ

**ប្រការ ៣.-** វិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ

វិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ត្រូវចែងអំពី ៖

១-វិធាន និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ទីផ្សារមូលបត្រ

២-វិធាន និងនីតិវិធីសម្រាប់គ្រប់គ្រងសមាជិកភាព និងការចូលរួមក្នុងទីផ្សារ

៣-វិធានចុះបញ្ជីរបស់ទីផ្សារមូលបត្រ

៤-លក្ខន្តិកៈរបស់ប្រតិបត្តិករ។

**ប្រការ ៤.-** វិធាន និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ទីផ្សារមូលបត្រ

វិធាន និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ត្រូវចែងអំពីវិធាន និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការជួញដូរមូលបត្រ តាមប្រភេទនីមួយៗ។ វិធាន និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការទាំងនេះ ត្រូវចែងជាអប្បបរមានូវ ៖

១-ពេលវេលានៃការជួញដូរ។

២-ប្រភេទនៃមូលបត្រដែលត្រូវធ្វើការជួញដូរ។

៣-ព័ត៌មានដែលត្រូវមានក្នុងការបញ្ជាទិញ-លក់។

៤-វិធីសាស្ត្រ និងយន្តការអនុវត្តការជួញដូរ។

៥-វិធានការក្នុងករណីដែលប្រព័ន្ធជួញដូរជួបប្រទះបញ្ហាដោយថាហេតុ។

៦-ព័ត៌មានដែលត្រូវផ្សព្វផ្សាយជាសាធារណៈទាក់ទងនឹងការជួញដូរ និងព័ត៌មានដែលប្រតិបត្តិករទីផ្សារមូលបត្រត្រូវជូនដំណឹងទៅសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ។

៧-កម្រៃប្រតិបត្តិការ និងកម្រៃផ្សេងទៀត។

៨-នីតិវិធីសម្រាប់ឃ្លាំមើលប្រតិបត្តិការជួញដូរ។

**ប្រការ ៥.-** វិធាន និងនីតិវិធីសម្រាប់គ្រប់គ្រងសមាជិកភាពនិងការចូលរួមក្នុងទីផ្សាររបស់ប្រតិបត្តិករទីផ្សារមូលបត្រ

វិធាន និងនីតិវិធីសម្រាប់គ្រប់គ្រងសមាជិកភាព និងការចូលរួមក្នុងទីផ្សារ របស់ប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវចែងជាអប្បបរមានូវ ៖

១-ប្រភេទនៃសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ។

២-លក្ខខណ្ឌ និងនីតិវិធី ដើម្បីក្លាយជាសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ។

៣-លក្ខខណ្ឌ និងនីតិវិធី ដើម្បីលុប ដកហូតសមាជិកភាព បញ្ឈប់មិនឱ្យចូលរួមក្នុងទីផ្សារ អនុញ្ញាតឱ្យចូលរួមជាថ្មីក្នុងទីផ្សារ ឬអនុញ្ញាតជាថ្មីជាសមាជិក។

៤-សិទ្ធិ និងកាតព្វកិច្ចរបស់សមាជិក និងអ្នកចូលរួមក្នុងទីផ្សារ ដែលធានាបាននូវសមភាពរវាងសមាជិក និងអ្នកចូលរួមក្នុងទីផ្សារទាំងអស់។

៥-កាតព្វកិច្ចដែលតម្រូវឱ្យសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ គោរពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៦-និទ្ទេសដែលតម្រូវឱ្យសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ ចែងនៅក្នុងកិច្ចព្រមព្រៀងសេវាដែលនឹងធ្វើជាមួយអតិថិជន។

៧-នីតិវិធីទាក់ទងនឹងការត្រួតពិនិត្យជាប្រចាំ និងដោយឥតព្រាងទុកនូវការអនុវត្តវិធានប្រតិបត្តិការរបស់ប្រតិបត្តិករទីផ្សារមូលបត្រដោយសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ ពិសេសនីតិវិធីស្តីពីការធ្វើអធិការកិច្ចលើសកម្មភាពជួញដូរ និងលើស្ថានភាពហិរញ្ញវត្ថុរបស់សមាជិក និងអ្នកចូលរួមក្នុងទីផ្សារ។

៨-ពេលវេលា និងប្រភេទនៃព័ត៌មានដែលសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ ត្រូវផ្តល់ដល់ប្រតិបត្តិករទីផ្សារមូលបត្រ។

៩-វិធានការខាងវិន័យ និងទណ្ឌកម្មចំពោះសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ ដោយចែងឱ្យបានច្បាស់លាស់នូវមូលហេតុ និងប្រភេទនៃវិធានការដែលត្រូវអនុវត្ត ព្រមទាំងនីតិវិធីនៃការជូនដំណឹង។

១០-វិធានការដែលត្រូវចាត់ដោយសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ ចំពោះអតិថិជនដែលធ្វើឱ្យការជួញដូរមិនបានសម្រេច។

១១-ប្រភេទសេវានានាដែលត្រូវផ្តល់ឱ្យសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ និងកម្រៃសេវាទាំងនោះ។

**ប្រការ ៦.-** វិធានចុះបញ្ជីរបស់ទីផ្សារមូលបត្រ

វិធានចុះបញ្ជីរបស់ទីផ្សារមូលបត្រ ត្រូវចែងជាអប្បបរមានូវ ÷

១-លក្ខខណ្ឌដើម្បីចុះបញ្ជីលក់មូលបត្រ។

២-នីតិវិធីនៃការពិនិត្យពីលទ្ធភាពដែលអាចចុះបញ្ជីលក់មូលបត្រ។

៣-លក្ខខណ្ឌ និងនីតិវិធី ដើម្បីព្យួរ និងដកចេញពីបញ្ជីលក់មូលបត្រ។

៤-កាតព្វកិច្ច និងនីតិវិធីនៃការផ្តល់ឯកសារផ្តល់ព័ត៌មានរបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ។

៥-ប្រភេទសេវានានាដែលត្រូវផ្តល់ឱ្យក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ និងកម្រៃសេវាទាំងនោះ។

## ជំពូកទី ៣
## មាតិកាគោលនៃវិធានប្រតិបត្តិការរបស់ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ

**ប្រការ ៧.-** វិធាន និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ

វិធាន និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រត្រូវចែងជាអប្បបរមានូវ ÷

១-ពេលវេលានៃការជាត់ទាត់ និងទូទាត់។

២-បំណាត់ថ្នាក់ ឬប្រភេទនៃប្រតិបត្តិការដែលត្រូវជាត់ទាត់ និងទូទាត់។

៣-ការបើក និងការគ្រប់គ្រងគណនីជាត់ទាត់ និងទូទាត់មូលបត្រ។

៤-នីតិវិធីនៃប្រតិបត្តិការជាត់ទាត់ និងទូទាត់។

៥-វិធានសម្រាប់គ្រប់គ្រងការផ្ទេរកម្មសិទ្ធិ ផ្ទួនឹងការទូទាត់សាច់ប្រាក់ ឬ ឌីវីភី (Delivery Vs. Payment - DVP)។

៦-ភាគរយនៃមូលបត្រ និងសាច់ប្រាក់ដែលសមាជិក និងអ្នកចូលរួមក្នុងទីផ្សារត្រូវមាននៅក្នុងគណនីរបស់ខ្លួន នៅពេលធ្វើប្រតិបត្តិការផ្ទេរមូលបត្រ និងទូទាត់សាច់ប្រាក់។

៧-នីតិវិធីនៃការផ្តល់របាយការណ៍អំពីប្រតិបត្តិការជាត់ទាត់និងទូទាត់ ឱ្យប្រតិបត្តិករទីផ្សារមូលបត្រ។

៨-វិធាន និងនីតិវិធីដែលត្រូវអនុវត្តនៅពេលដែលសមាជិក ឬអ្នកចូលរួម គ្មានលទ្ធភាព ឬអាចគ្មានលទ្ធភាពក្នុងការធ្វើប្រតិបត្តិការជាត់ទាត់និងទូទាត់។

៩-នីតិវិធីដែលត្រូវអនុវត្តនៅពេលប្រតិបត្តិការផ្ទេរមូលបត្រមិនបានសម្រេច ឬមូលបត្រដែលត្រូវផ្ទេរមិនបានចុះបញ្ជីត្រឹមត្រូវ។

**ប្រការ ៨.-** វិធាន និងនីតិវិធីសម្រាប់គ្រប់គ្រងសមាជិកភាព និងការចូលរួមក្នុងទីផ្សាររបស់ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ

វិធាន និងនីតិវិធីសម្រាប់គ្រប់គ្រងសមាជិកភាព និងការចូលរួមក្នុងទីផ្សាររបស់ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ត្រូវចែងជាអប្បបរមានូវ ÷

១-ប្រភេទនៃសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ។

២-លក្ខខណ្ឌ និងនីតិវិធី ដើម្បីក្លាយជាសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ។

៣-លក្ខខណ្ឌ និងនីតិវិធី ដើម្បីព្យួរ ដកហូតសមាជិកភាព បញ្ឈប់មិនឱ្យចូលរួមក្នុងទីផ្សារ អនុញ្ញាតឱ្យចូលរួមជាថ្មីក្នុងទីផ្សារ ឬអនុញ្ញាតជាថ្មីជាសមាជិក។

៤-សិទ្ធិ និងកាតព្វកិច្ចរបស់សមាជិក និងអ្នកចូលរួមក្នុងទីផ្សារ ដែលធានាបាននូវសមភាពរវាងសមាជិក និងអ្នកចូលរួមក្នុងទីផ្សារទាំងអស់។

៥-ប្រភេទសេវានានាដែលត្រូវផ្តល់ឱ្យសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ និងកម្រៃសេវាទាំងនោះ។

៦-ប្រភេទព័ត៌មានដែលសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ ត្រូវរក្សាទុក។

៧-លក្ខខណ្ឌដែលតម្រូវឱ្យសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ បង់វិភាគទានចូលមូលនិធិធានាការទូទាត់សង (Compensation Fund)។

៨-នីតិវិធីនៃការត្រួតពិនិត្យ ដឹកនាំកែតម្រង់ និងចាត់វិធានការខាងវិន័យ និងទណ្ឌកម្មនានាចំពោះសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ ដែលមិនគោរពតាមវិធាន និងនីតិវិធី។

## ជំពូកទី ៤
## មាតិកាគោលនៃវិធានប្រតិបត្តិការរបស់សេវារក្សាទុកមូលបត្រ

**ប្រការ ៩.-** វិធាន និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការរបស់សេវារក្សាទុកមូលបត្រ

វិធាន និងនីតិវិធីពាក់ព័ន្ធនឹងប្រតិបត្តិការរបស់សេវារក្សាទុកមូលបត្រ ត្រូវចែងជាអប្បបរមានូវ ÷

១-ពេលវេលានៃការធ្វើប្រតិបត្តិការប្រចាំថ្ងៃ។

២-ការកំណត់ប្រភេទ ឬគុណវុឌ្ឍិមូលបត្រដែលអាចទទួលរក្សាទុក។

៣-ការបើក និងបិទគណនីរបស់អ្នកផ្ញើ។

៤-ការរៀបចំ និងការរក្សាទុកសៀវភៅគណនីរបស់អ្នកផ្ញើ។

៥-ការដាក់ផ្ញើ ការដក និងការបង្វិលទៅវិញនូវមូលបត្រដែលដាក់ផ្ញើ។

៦-ការផ្ទេរមូលបត្ររវាងគណនី។

៧-នីតិវិធីនៃការគ្រប់គ្រង និងរក្សាទុកមូលបត្រដែលបានដាក់ផ្ញើ។

៨-នីតិវិធីនៃការអនុវត្តសិទ្ធិដែលទទួលបានពីមូលបត្រដែលដាក់ផ្ញើ។

៩-លក្ខខណ្ឌ និងនីតិវិធីនៃការបញ្ចាំមូលបត្រដែលដាក់ផ្ញើ។

**ប្រការ ១០.-** វិធាន និងនីតិវិធីសម្រាប់គ្រប់គ្រងសមាជិកភាព ឬការចូលរួមក្នុងទីផ្សាររបស់សេវារក្សាទុកមូលបត្រ

វិធាន និងនីតិវិធីសម្រាប់គ្រប់គ្រងសមាជិកភាព ឬការចូលរួមក្នុងទីផ្សាររបស់សេវារក្សាទុកមូលបត្រ ត្រូវចែងជាអប្បបរមានូវ ៖

១-ប្រភេទនៃសមាជិក ឬអ្នកចូលរួមក្នុងទីផ្សារ។

២-លក្ខខណ្ឌដើម្បីក្លាយជាសមាជិក ឬអ្នកចូលរួមក្នុងទីផ្សារ។

៣-លក្ខខណ្ឌ និងនីតិវិធី ដើម្បីព្យួរ ដកហូតសមាជិកភាព បញ្ឈប់មិនឱ្យចូលរួមក្នុងទីផ្សារ អនុញ្ញាតឱ្យចូលរួមជាថ្មីក្នុងទីផ្សារ ឬអនុញ្ញាតជាថ្មីជាសមាជិក។

៤-សិទ្ធិ និងកាតព្វកិច្ចរបស់សមាជិក ឬអ្នកចូលរួមក្នុងទីផ្សារដែលធានាបាននូវសមភាពរវាងសមាជិក ឬអ្នកចូលរួមក្នុងទីផ្សារទាំងអស់។

៥-និទ្ទេសដែលតម្រូវឱ្យសមាជិក ឬអ្នកចូលរួមក្នុងទីផ្សារ ចែងនៅក្នុងកិច្ចព្រមព្រៀងសេវាដែលនឹងធ្វើជាមួយអតិថិជន។

៦-ប្រភេទសេវាដែលត្រូវផ្តល់ឱ្យសមាជិក ឬអ្នកចូលរួមក្នុងទីផ្សារ និងកម្រៃសេវាទាំងនោះ។

៧-នីតិវិធីនៃការត្រួតពិនិត្យ ដឹកនាំកែតម្រង់ និងចាត់វិធានការខាងវិន័យ និងទណ្ឌកម្មនានាចំពោះសមាជិក ឬអ្នកចូលរួមក្នុងទីផ្សារ ដែលមិនគោរពតាមវិធានប្រតិបត្តិការ និងនីតិវិធី។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**ប្រការ ១១.-** បដិវាទកម្ម

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១២.- ការអនុវត្ត**

អគ្គនាយក អគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១០

**គាត ឈន់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ

  "ដើម្បីជូនជ្រាប"

- គណៈកម្មការមូលបត្រកម្ពុជា
- ដូចប្រការ ១២

  "ដើម្បីអនុវត្ត"

- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ: ០០៥ គ.ម.ក.ប្រក

លិខិតចូល
ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ2010

## ប្រកាស
## ស្តីពី
## ការទទួលស្គាល់ក្រុមហ៊ុនគណនេយ្យជំនាញ ផ្តល់សេវានៅក្នុងវិស័យមូលបត្រ

*****

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh

- បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ/បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០

## ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-** គោលបំណង

ប្រកាសនេះមានគោលបំណងចែងពីលក្ខខណ្ឌតម្រូវដើម្បីទទួលស្គាល់ និងកំណត់អំពីកាតព្វកិច្ចរបស់ក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ ដែលផ្តល់សេវានៅក្នុងវិស័យមូលបត្រ ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-** និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ៖

១-ក្រមសីលធម៌ សំដៅដល់ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គណនេយ្យករជំនាញ និងសវនករប្រតិស្រុត ដែលប្រកាសឱ្យប្រើដោយស្ថាប័នមានសមត្ថកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២-ក្រុមហ៊ុនគណនេយ្យជំនាញ សំដៅដល់ក្រុមហ៊ុនគណនេយ្យដែលបង្កើតឡើងស្របតាមច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យនៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

៣-សមាជិកគ្រួសារផ្ទាល់ សំដៅដល់ទំនាក់ទំនងជាប្តី ប្រពន្ធ កូន ឪពុក ម្តាយ បងប្អូនប្រុស ឬបងប្អូនស្រីរបស់បុគ្គលណាម្នាក់។

៤-សវនករឯករាជ្យ សំដៅដល់សវនករប្រតិស្រុតដែលជាសមាជិកសកម្មរបស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (វ.គ.ស.ក.) ហើយបម្រើការងារនៅក្នុងក្រុមហ៊ុនគណនេយ្យជំនាញ។

៥-សវនកម្ម សំដៅដល់ការត្រួតពិនិត្យឡើងវិញ ឬការត្រួតពិនិត្យប្រកបដោយលក្ខណៈជាប្រព័ន្ធ ទៅលើការអះអាង ឬលើសកម្មភាព ឬរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពអាជីវកម្ម ដើម្បីឱ្យអង្គភាពនោះ គោរពតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

## ជំពូកទី ២

## លក្ខខណ្ឌ និងនីតិវិធីសម្រាប់ការទទួលស្គាល់ក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ

**ប្រការ ៣.-** លក្ខខណ្ឌសម្រាប់ការទទួលស្គាល់ក្រុមហ៊ុនគណនេយ្យជំនាញ

ក្រុមហ៊ុនគណនេយ្យជំនាញដែលដាក់ពាក្យស្នើសុំការទទួលស្គាល់ នៅគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម ÷

១-ត្រូវធ្វើប្រតិបត្តិការស្របតាមច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

២-ត្រូវមានដើមទុនយ៉ាងតិចចំនួន ៥០០.០០០.០០០ (ប្រាំរយលាន) រៀល។

៣-ត្រូវមានសវនករឯករាជ្យយ៉ាងតិចចំនួន ០៥ (ប្រាំ) រូប ដែលសវនករឯករាជ្យទាំងនោះត្រូវបំពេញនូវលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ។

៤-ត្រូវមានការធានារ៉ាប់រងវិជ្ជាជីវៈសម្រាប់ក្រុមហ៊ុន និងសម្រាប់សវនករឯករាជ្យរបស់ក្រុមហ៊ុន ដែលបានទទួលស្គាល់ដោយ គ.ម.ក.។

៥-ត្រូវបានបង្កើត និងមានសកម្មភាពធុរកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាយ៉ាងហោចណាស់ ០៥ (ប្រាំ) ឆ្នាំ គិតមកដល់ថ្ងៃដាក់ពាក្យស្នើសុំការទទួលស្គាល់មក **គ.ម.ក.**។

៦-ត្រូវមានកេរ្តិ៍ឈ្មោះល្អក្នុងសកម្មភាពធុរកិច្ចសវនកម្ម។

៧-ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយសវនករឯករាជ្យសម្រាប់រយៈពេល ០៣ (បី) ឆ្នាំចុងក្រោយ។

៨-មានអតិថិជនយ៉ាងតិច ៣០ (សាមសិប) ក្នុងមួយឆ្នាំ ដែលក្នុងនោះ ៥០ (ហាសិប) ភាគរយ ជាអតិថិជនដែលក្រុមហ៊ុនបានផ្តល់សេវាសវនកម្ម។

៩-ត្រូវដាក់ពាក្យស្នើសុំទទួលស្គាល់ដើម្បីផ្តល់សេវាក្នុងវិស័យមូលបត្រមក **គ.ម.ក.** ដោយអនុលោមតាមប្រការ ៤ នៃប្រកាសនេះ។

**ប្រការ ៤.-** ពាក្យស្នើសុំសម្រាប់ការទទួលស្គាល់ក្រុមហ៊ុនគណនេយ្យជំនាញ

ក្រុមហ៊ុនគណនេយ្យជំនាញដែលដាក់ពាក្យស្នើសុំការទទួលស្គាល់ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយ **គ.ម.ក.** និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ÷

១-វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម។

២-វិញ្ញាបនបត្រចុះបញ្ជីជាសមាជិក **វ.គ.ស.ក.**។

៣-សេចក្តីសម្រេចពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៤-បញ្ជីសវនករឯករាជ្យមានលក្ខណៈបច្ចុប្បន្នភាព ដែលបានចុះឈ្មោះជាសមាជិកសកម្មដោយមានការបញ្ជាក់ពី **វ.គ.ស.ក.** និងភ្ជាប់មកជាមួយនូវប្រវត្តិរូបរបស់សវនករឯករាជ្យទាំងអស់ ដោយបញ្ជាក់ពីរយៈពេលបំពេញការងារ ព្រមទាំងបទពិសោធន៍។

៥-របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មក្នុងរយៈពេល ០៣ (បី) ឆ្នាំចុងក្រោយ មុនពេលដាក់ពាក្យស្នើសុំការទទួលស្គាល់។

៦-បញ្ជីឈ្មោះអតិថិជនដែលបានធ្វើសវនកម្មនៅក្នុងរយៈពេល ០៣ (បី) ឆ្នាំចុងក្រោយ។

៧-របាយការណ៍ប្រតិបត្តិការសម្រាប់រយៈពេល ០៣ (បី) ឆ្នាំចុងក្រោយ។

៨-របាយការណ៍ស្តីពីការប្រែប្រួលសំខាន់ៗដែលមានផលប៉ះពាល់ដល់ដំណើរការ និងលទ្ធផល ក្នុងរយៈពេល ០៣ (បី) ឆ្នាំចុងក្រោយ។

៩-របាយការណ៍ស្តីពីការប្រែប្រួលសំខាន់ៗពាក់ព័ន្ធនឹងសវនករឯករាជ្យ ដូចជាការកើនឬការថយចុះនៃចំនួនសវនករឯករាជ្យ ការបំពានបទប្បញ្ញត្តិ និងក្រមសីលធម៌របស់សវនករឯករាជ្យជាដើម ក្នុងរយៈពេល ០៣ (បី) ឆ្នាំចុងក្រោយ។

១០-ឯកសារផ្សេងទៀតតាមការស្នើសុំរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៥.-** លក្ខខណ្ឌសម្រាប់ការទទួលស្គាល់សវនករឯករាជ្យ

សវនករឯករាជ្យនៃក្រុមហ៊ុនគណនេយ្យជំនាញដែលស្នើសុំការទទួលស្គាល់នៅ **គ.ម.ក.** ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម ៖

១-បានចុះឈ្មោះជាសមាជិកសកម្មរបស់ **វ.គ.ស.ក.**។ ករណីសវនករឯករាជ្យជាជនបរទេសត្រូវមានទីលំនៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២-ត្រូវមានបទពិសោធន៍យ៉ាងតិចចំនួន ០៥ (ប្រាំ) ឆ្នាំ ក្នុងធុរកិច្ចសវនកម្ម។

៣-មិនធ្លាប់ត្រូវបានផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬការប្រព្រឹត្តល្មើសនឹងក្រមសីលធម៌។

៤-មិនធ្លាប់ត្រូវបានផ្តន្ទាទោសជាស្ថាពរពីបទមជ្ឈិម ក្នុងរយៈពេល ១០ (ដប់) ឆ្នាំ មុនពេលដាក់ពាក្យស្នើសុំ។

៥-ត្រូវដាក់ពាក្យស្នើសុំទទួលស្គាល់ដើម្បីផ្តល់សេវាក្នុងវិស័យមូលបត្រមក **គ.ម.ក.** ដោយអនុលោមតាមប្រការ ៦ នៃប្រកាសនេះ។

**ប្រការ ៦.-** ពាក្យស្នើសុំសម្រាប់ការទទួលស្គាល់សវនករឯករាជ្យ

សវនករឯករាជ្យដែលដាក់ពាក្យស្នើសុំការទទួលស្គាល់ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយ **គ.ម.ក.** និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ៖

១-សញ្ញាបត្រគណនេយ្យករជំនាញ (Certified Public Accountant-CPA) ឬសញ្ញាបត្រសមមូល។

២-វិញ្ញាបនបត្រចុះឈ្មោះជាសមាជិកសកម្ម **វ.គ.ស.ក.**។

៣-លិខិតបញ្ជាក់ថា សវនករឯករាជ្យមិនធ្លាប់បានទទួលទណ្ឌកម្មរដ្ឋបាល។

៤-លិខិតថ្កោលទោសដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

៥-ឯកសារផ្សេងទៀតតាមការស្នើសុំរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៧.-** សុពលភាពនៃការទទួលស្គាល់ក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ

ការទទួលស្គាល់ក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ មានសុពលភាពរយៈពេល ០៣ (បី) ឆ្នាំ។ ក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ មុនការទទួលស្គាល់អស់សុពលភាព ក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ ដែលមានបំណងបន្តផ្តល់សេវា ត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពនៃការទទួលស្គាល់តាមទម្រង់ដែលកំណត់ដោយ **គ.ម.ក.**។

ករណីក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ មិនបានស្នើសុំបន្តការទទួលស្គាល់មុនរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ នៃថ្ងៃអស់សុពលភាពការទទួលស្គាល់ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ ក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ ត្រូវធ្វើការស្នើសុំការទទួលស្គាល់ឡើងវិញ និងត្រូវទទួលទណ្ឌកម្មវិន័យអន្តរការណ៍ដូចមានចែងក្នុងកថាខណ្ឌទី ៣ នៃប្រការ ២៤ នៃប្រកាសនេះ។

**ប្រការ ៨.–** រយៈពេលនៃការជូនដំណឹងចំពោះបុគ្គលដាក់ពាក្យស្នើសុំ

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងអំពីការទទួលស្គាល់ ឬការមិនទទួលស្គាល់ក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ ក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ បន្ទាប់ពីទទួលបានឯកសារពេញលេញ។

## ជំពូកទី ៣

## លក្ខខណ្ឌប្រតិបត្តិការសម្រាប់ក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ ដែលទទួលបានការទទួលស្គាល់

**ប្រការ ៩.–** ការជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ

ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ប្រតិបត្តិកររក្សាទុកមូលបត្រ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ក្រុមហ៊ុនគណនេយ្យជំនាញ និងក្រុមហ៊ុនដទៃទៀតដែលធ្វើធុរកិច្ចនៅក្នុងវិស័យមូលបត្រ ត្រូវជ្រើសរើសក្នុងចំណោមក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ ដែលទទួលបានការទទួលស្គាល់ និងផ្សព្វផ្សាយជាផ្លូវការដោយ **គ.ម.ក.**។

**ប្រការ ១០.–** លក្ខខណ្ឌដែលមិនអនុញ្ញាតឱ្យធ្វើសវនកម្ម

មិនត្រូវបានអនុញ្ញាតឱ្យធ្វើសវនកម្មបានឡើយ ប្រសិនបើក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ ÷

១-មានទំនាក់ទំនងហិរញ្ញវត្ថុសំខាន់ជាមួយក្រុមហ៊ុនរងសវនកម្ម។

២-ជាសមាជិកគ្រួសារផ្ទាល់របស់អភិបាល អគ្គនាយក សវនករផ្ទៃក្នុង ប្រធានហិរញ្ញវត្ថុ ឬបុគ្គលិកជាន់ខ្ពស់ដទៃទៀត របស់ក្រុមហ៊ុនរងសវនកម្ម។

៣-មានទំនាក់ទំនងក្នុងការវិនិយោគរួមគ្នាជាមួយក្រុមហ៊ុនរងសវនកម្ម។

៤-មានភាគហ៊ុននៅក្នុងក្រុមហ៊ុនរងសវនកម្ម។

៥-ទទួលផលប្រយោជន៍ដោយផ្ទាល់ ឬដោយប្រយោលពីក្រុមហ៊ុនរងសវនកម្ម។

៦-មានទំនាក់ទំនងផ្សេងទៀតដែល **គ.ម.ក.** យល់ឃើញថាអាចបង្កឱ្យមានទំនាស់ផលប្រយោជន៍ជាមួយក្រុមហ៊ុនរងសវនកម្ម។

**ប្រការ ១១.-** សេវាមិនមែនសវនកម្មដែលត្រូវបានហាមឃាត់

ក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ មិនត្រូវផ្តល់ដល់ក្រុមហ៊ុនរងសវនកម្មនូវសេវាដូចខាងក្រោម ៖

១-ការកាន់បញ្ជីគណនេយ្យ ឬសេវាផ្សេងទៀតទាក់ទងនឹងកំណត់ត្រាគណនេយ្យ ឬរបាយការណ៍ហិរញ្ញវត្ថុ។

២-ការរៀបចំ និងការដាក់ឱ្យដំណើរការប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុ។

៣-សេវាវាយតម្លៃ ឬការប៉ាន់ស្មាន ការផ្តល់យោបល់ ឬការចូលរួមធ្វើរបាយការណ៍។

៤-សេវាពាក់ព័ន្ធនឹងការកំណត់សោធននិវត្តន៍បុគ្គលិក។

៥-សេវាសវនកម្មផ្ទៃក្នុង។

៦-សេវាមុខងារគ្រប់គ្រង ឬធនធានមនុស្ស។

៧-សេវាធានាទិញមូលបត្រ ជួញដូរមូលបត្រ ជើងសាមូលបត្រ ឬផ្តល់ប្រឹក្សាវិនិយោគ។

៨-សេវាផ្នែកច្បាប់។

៩-សេវាប្រឹក្សាផ្នែកពន្ធ។

១០-សេវាផ្សេងទៀតដែល **គ.ម.ក.** យល់ឃើញថា អាចបង្កឱ្យមានទំនាស់ផល-ប្រយោជន៍។

ករណីក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ បានផ្តល់សេវាដូចបានរៀបរាប់ខាងលើ ដល់ក្រុមហ៊ុនណាមួយ ក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ មិនត្រូវបានអនុញ្ញាតឱ្យចុះកិច្ចសន្យាផ្តល់សេវាសវនកម្មដល់ក្រុមហ៊ុននោះបានឡើយ ក្នុងរយៈពេល ០១ (មួយ) ឆ្នាំ ក្រោយកិច្ចសន្យាផ្តល់សេវាខាងលើបានបញ្ចប់។

## ជំពូកទី ៤
## ភារកិច្ចរបស់ក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ ដែលទទួលបានការទទួលស្គាល់

**ប្រការ ១២.-** របាយការណ៍ហិរញ្ញវត្ថុដែលត្រូវធ្វើសវនកម្ម ឬពិនិត្យឡើងវិញ

ក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ មានកាតព្វកិច្ចធ្វើសវនកម្ម និង ពិនិត្យឡើងវិញនូវរបាយការណ៍ហិរញ្ញវត្ថុដូចខាងក្រោម ÷

១-របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

២-របាយការណ៍លទ្ធផល។

៣-របាយការណ៍លំហូរសាច់ប្រាក់។

៤-របាយការណ៍ស្តីពីការប្រែប្រួលក្នុងមូលធន។

៥-កំណត់សម្គាល់។

៦-របាយការណ៍ផ្សេងទៀតទៅតាមការតម្រូវរបស់ **គ.ម.ក.**។

**ប្រការ ១៣.-** ការអនុវត្តស្តង់ដារ

ក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវស្តង់ដារ ដូចខាងក្រោម ÷

១-ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ដែលបានអនុម័តឱ្យ ប្រើនៅព្រះរាជាណាចក្រកម្ពុជា។

២-ស្តង់ដារសវនកម្មដែលបានអនុម័តឱ្យប្រើនៅព្រះរាជាណាចក្រកម្ពុជា។

៣-ក្រមសីលធម៌។

៤-ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**ប្រការ ១៤.-** កាតព្វកិច្ចរបស់ក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យដែលទទួល បានការទទួលស្គាល់

ក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ ដែលទទួលបានការទទួលស្គាល់ ត្រូវមានកាតព្វកិច្ចដូចខាងក្រោម ÷



១-ត្រូវផ្តល់ការពន្យល់ ឬផ្តល់ព័ត៌មាន និងទិន្នន័យដែលទាក់ទងនឹងសកម្មភាពសវនកម្ម ករណីមានការស្នើសុំដោយអគ្គនាយកនៃ **គ.ម.ក.**។

២-នៅពេលធ្វើសវនកម្ម ប្រសិនបើរកឃើញថារបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម មិនបានអនុវត្តទៅតាមច្បាប់ និងបទប្បញ្ញត្តិនានាដូចមានចែងក្នុងប្រការ ១៣ នៃប្រកាសនេះ ត្រូវជូនដំណឹងដល់ក្រុមហ៊ុនរងសវនកម្ម និងស្នើឡើងនូវវិធានការការពារ កែតម្រូវ និងដោះស្រាយចំពោះការបំពានទាំងនោះ ព្រមទាំងផ្តល់នូវអនុសាសន៍ចំពោះកំហុស ឬការបំពាននានា ដែលមិនទាន់បានដោះស្រាយស្របទៅតាមស្តង់ដារសវនកម្ម ហើយត្រូវរាយការណ៍ក្នុងរបាយការណ៍សវនកម្ម និងរបាយការណ៍ស្តីពីការវាយតម្លៃស្ថានភាពរបស់ក្រុមហ៊ុន។

៣-ត្រូវរាយការណ៍ជូនអគ្គនាយកនៃ **គ.ម.ក.** នៅពេលរកឃើញភាពមិនប្រក្រតីដូចខាងក្រោម ÷

ក-ការគៃបន្លំ ឬកំហុសសំខាន់ៗដែលមានផលប៉ះពាល់ដល់ការសម្រេចចិត្តរបស់វិនិយោគិនមូលបត្រ ឬបុគ្គលពាក់ព័ន្ធដទៃទៀត។

ខ-ការបាត់បង់ ឬការបាត់បង់ជាសក្តានុពលសរុបចាប់ពី ១០ (ដប់) ភាគរយនៃទ្រព្យសកម្មសរុបរបស់ក្រុមហ៊ុនរងសវនកម្ម។

គ-ទ្រព្យសកម្មរបស់ក្រុមហ៊ុន មិនគ្រប់គ្រាន់សម្រាប់ទូទាត់ឱ្យម្ចាស់បំណុលរបស់ក្រុមហ៊ុនរងសវនកម្ម។

៤-រាល់ការសុំឈប់ ការបញ្ឈប់ ឬការផ្អាក សេវាក្នុងវិស័យមូលបត្រ ក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ ត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរជូនអគ្គនាយកនៃ **គ.ម.ក.** ក្នុងរយៈពេលមិនលើសពី ០៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ។

៥-នៅក្នុងកិច្ចសន្យាធ្វើសវនកម្មជាមួយអតិថិជន ត្រូវមានចែងអំពីសិទ្ធិរបស់ក្រុមហ៊ុនគណនេយ្យជំនាញ ឬសវនករឯករាជ្យ ក្នុងការផ្តល់ព័ត៌មាន ឬផ្តល់របាយការណ៍សវនកម្មជូន **គ.ម.ក.**។

៦-ករណីអគ្គនាយកនៃ **គ.ម.ក.** តម្រូវឱ្យក្រុមហ៊ុនគណនេយ្យជំនាញពិនិត្យឡើងវិញចំពោះចំនុចមួយចំនួនដែលមិនមានភាពច្បាស់លាស់ ក្រុមហ៊ុនគណនេយ្យជំនាញត្រូវអនុវត្តតាមការស្នើសុំរបស់អគ្គនាយកនៃ **គ.ម.ក.**។

៧-ករណី **គ.ម.ក.** រកឃើញថាក្រុមហ៊ុនគណនេយ្យជំនាញបានចេញនូវរបាយការណ៍សវនកម្មដែលមិនត្រឹមត្រូវ ហើយបណ្តាលឱ្យមានការខូចខាតដល់ក្រុមហ៊ុនរងសវនកម្ម និង

អ្នកប្រើប្រាស់របាយការណ៍សវនកម្ម ក្រុមហ៊ុនគណនេយ្យជំនាញត្រូវទូទាត់សង ទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៨-ក្រុមហ៊ុនគណនេយ្យជំនាញត្រូវផ្តល់របាយការណ៍អាជីវកម្មក្នុងវិស័យមូលបត្ររបស់ខ្លួនមក **គ.ម.ក.** ប្រចាំត្រីមាស ក្នុងរយៈពេល ០១ (មួយ) ខែ បន្ទាប់ពីដំណាច់ត្រីមាសនីមួយៗ និងត្រូវផ្តល់របាយការណ៍ប្រចាំឆ្នាំ ក្នុងរយៈពេល ០៣ (បី) ខែ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ។

៩-ក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យ ត្រូវអនុវត្តកាតព្វកិច្ចផ្សេងទៀតដែលតម្រូវដោយ **គ.ម.ក.**។

## ជំពូកទី ៥
## កម្រៃ និងបន្ទុក

**ប្រការ ១៥.-** ថ្លៃពាក្យស្នើសុំការទទួលស្គាល់របស់ក្រុមហ៊ុនគណនេយ្យជំនាញ

ក្រុមហ៊ុនគណនេយ្យជំនាញត្រូវបង់ថ្លៃពាក្យស្នើសុំការទទួលស្គាល់ និងសោហ៊ុយសិក្សាសំណុំលិខិតជាសាច់ប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀល។

ក្រុមហ៊ុនគណនេយ្យជំនាញត្រូវបង់ថ្លៃពាក្យស្នើសុំបន្តការទទួលស្គាល់ និងសោហ៊ុយសិក្សាសំណុំលិខិតជាសាច់ប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល។

**ប្រការ ១៦.-** ថ្លៃពាក្យស្នើសុំការទទួលស្គាល់របស់សវនករឯករាជ្យ

សវនករឯករាជ្យត្រូវបង់ថ្លៃពាក្យស្នើសុំការទទួលស្គាល់ និងសោហ៊ុយសិក្សាសំណុំលិខិតជាសាច់ប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល។

សវនករឯករាជ្យត្រូវបង់ថ្លៃពាក្យស្នើសុំបន្តការទទួលស្គាល់ និងសោហ៊ុយសិក្សាសំណុំលិខិតជាសាច់ប្រាក់ចំនួន ៥០០.០០០ (ប្រាំរយពាន់) រៀល។

**ប្រការ ១៧.-** ថ្លៃសេវាទទួលស្គាល់ប្រចាំឆ្នាំសម្រាប់ក្រុមហ៊ុនគណនេយ្យជំនាញ

ក្រុមហ៊ុនគណនេយ្យជំនាញដែលទទួលបានការទទួលស្គាល់ ត្រូវបង់ថ្លៃសេវាទទួលស្គាល់ប្រចាំឆ្នាំជូន **គ.ម.ក.** ជាសាច់ប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀល ដោយគិតចាប់ពីកាលបរិច្ឆេទនៃការទទួលស្គាល់។ សម្រាប់ឆ្នាំដំបូង សេវាទទួលស្គាល់ប្រចាំឆ្នាំត្រូវបង់នៅពេលដែលទទួលបានការទទួលស្គាល់។ សម្រាប់ឆ្នាំបន្តបន្ទាប់ សេវាទទួលស្គាល់ប្រចាំឆ្នាំត្រូវបង់យ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃខែដែលទទួលបានការទទួលស្គាល់។

**ប្រការ ១៨.-** ថ្លៃសេវាទទួលស្គាល់ប្រចាំឆ្នាំសម្រាប់សវនករឯករាជ្យ

សវនករឯករាជ្យដែលទទួលបានការទទួលស្គាល់ ត្រូវបង់ថ្លៃសេវាទទួលស្គាល់ប្រចាំឆ្នាំជូន **គ.ម.ក** ជាសាច់ប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ដោយគិតចាប់ពីកាលបរិច្ឆេទនៃការទទួលស្គាល់។ សម្រាប់ឆ្នាំដំបូង សេវាទទួលស្គាល់ប្រចាំឆ្នាំត្រូវបង់នៅពេលដែលទទួលបានការទទួលស្គាល់។ សម្រាប់ឆ្នាំបន្តបន្ទាប់ សេវាទទួលស្គាល់ប្រចាំឆ្នាំត្រូវបង់យ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃខែដែលទទួលបានការទទួលស្គាល់។

**ប្រការ ១៩.-** ការបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិត និងថ្លៃសេវាទទួលស្គាល់

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិត និងថ្លៃសេវាទទួលស្គាល់ប្រចាំឆ្នាំដែលបានបង់មក **គ.ម.ក.** មិនអាចដកវិញបានឡើយ ទោះជាបុគ្គលទទួលបាន ឬមិនទទួលបានការទទួលស្គាល់ ឬការទទួលស្គាល់ត្រូវបានព្យួរ ឬដកហូត។

## ជំពូកទី ៦
## ការព្យួរ និងការដកហូតការទទួលស្គាល់

**ប្រការ ២០.-** ការព្យួរការទទួលស្គាល់

